# រដ្ឋសភាអនុម័តវិសោធនកម្មច្បាប់បោះឆ្នោតដែលកំហិតសិទ្ធិឈរឈ្មោះរបស់អ្នកនយោបាយ




អ្នកសារព័ត៌មាន ថតរូបរបស់លោក ស ខេង ដែលកំពុងថ្លែងការពារ«វិសោធនកម្មច្បាប់បោះឆ្នោត» ពីក្នុងកញ្ចក់អេក្រង់ទូរទស្សន៍ ក្នុងរដ្ឋសភា នៅរាជធានីភ្នំពេញ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣។(លាស់ លីបលីប/ វីអូអេ)

ភ្នំពេញ — រដ្ឋសភាដែលគ្រប់គ្រងទាំងមូលដោយគណបក្សប្រជាជនកម្ពុជាបានអនុម័តសេចក្តីព្រាងវិសោធនកម្មច្បាប់បោះឆ្នោតទាំងស្រុងកាលពីថ្ងៃសុក្រ ដែលច្បាប់នេះនឹងកំហិតសិទ្ធិឈរឈ្មោះរបស់អ្នក

នយោបាយ និងធានាថា មន្ត្រីគណបក្សជំទាស់នឹងទៅបោះឆ្នោតនាខែកក្កដាខាងមុខ បើទោះមិនមានវត្តមានរបស់គណបក្សភ្លើងទៀន។

បើតាមវិសោធនកម្មច្បាប់នេះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កំណត់ថា លុះត្រាតែបេក្ខជនបានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលចំនួនពីរលើកចុងក្រោយជាប់គ្នា ទើបអាចឈរឈ្មោះឱ្យគេបោះឆ្នោតបាន លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក៏ត្រូវបានកំណត់ដូចគ្នានឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលតម្រូវឱ្យបេក្ខជនអនុវត្តសិទ្ធិបោះឆ្នោតនៃការបោះឆ្នោតជាសកលពីរដងជាប់គ្នា ទើបអាចឈរឈ្មោះបាន។

ក្នុងកិច្ចប្រជុំសភា អ្នកស្រី ក្រូច សំអាន តំណាងរាស្ត្រមួយរូប បានថ្លែងថា សម្រាប់ការបោះឆ្នោតព្រឹទ្ធសភា ដែលនឹងធ្វើឡើងនាខែកុម្ភៈ ឆ្នាំ ២០២៤ ដែលជាការបោះឆ្នោតអសកល ដែលអង្គបោះឆ្នោតមិនមែនប្រជាពលរដ្ឋទូទៅ ការតម្រូវឱ្យបោះឆ្នោតចំនួនពីរលើក មិនអាចអនុវត្តបានឡើយ។ អ្នកស្រីបន្ថែមថា ដើម្បីធានាសង្គតភាព និងអនុភាពនៃការអនុវត្តច្បាប់នេះ ក្រោយច្បាប់នេះចូលជាធរមាន នឹងមានការរៀបចំ

មាត្រាអន្តរបញ្ញត្តិសម្រាប់ការបោះឆ្នោតព្រឹទ្ធសភានីតិកាលទី ៥ ដែលចែងលក្ខខណ្ឌកំណត់យកតែការបោះឆ្នោតមួយដងប៉ុណ្ណោះ នោះបេក្ខជនអាចឈរឈ្មោះបានហើយ។

អ្នកស្រីបញ្ជាក់ថា៖ «មានន័យថា នឹងអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅក្នុងឆ្នាំ ២០២៤ លុះត្រាតែបានទៅបោះឆ្នោត ជាសកលនៅឆ្នាំ ២០២៣ នេះ»។

លក្ខខណ្ឌសម្រាប់បេក្ខជនឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាវិញ បេក្ខជនអាចឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យបាន លុះត្រាតែបេក្ខជនបានអនុវត្តសិទ្ធិបោះឆ្នោតដោយបោះឆ្នោតសម្រាប់ការបោះឆ្នោតសកលលើកចុងក្រោយ លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះ មានមូលហេតុសមស្រប។

លោក ស ខេង ជាតំណាងរាស្ត្រមួយរូប និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា វិសោធនកម្មនេះកំហិតតែលក្ខខណ្ឌសម្រាប់អ្នកដែលឈរឈ្មោះឱ្យគេបោះឆ្នោតប៉ុណ្ណោះ។ ដូច្នេះលោកថា វាមិនប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋឡើយ។ លោកបន្ថែមថា ការទៅបោះឆ្នោតឬមិនទៅបោះឆ្នោត នៅតែជាសិទ្ធិរបស់ពលរដ្ឋខ្មែរ មិនមែនជាកាតព្វកិច្ចដែលមានចរិតជាការចាប់បង្ខំឡើយ។

លោកថ្លែងការពារវិសោធនកម្មច្បាប់បោះឆ្នោត នៅក្នុងអង្គប្រជុំពេញអង្គរដ្ឋសភា នៅថ្ងៃសុក្រនេះថា៖ «ជារួម វិសោធនកម្មច្បាប់បោះឆ្នោតពេលនេះ គឺត្រូវបានធ្វើឡើងក្នុងគោលបំណងការពារដំណើរការនៃការបោះឆ្នោតពីផែនការ ឬឧបាកលនយោបាយនានាលើការប៉ុនប៉ងបំផ្លាញការបោះឆ្នោត។ ហើយការធ្វើវិសោធនកម្មនេះ ក៏នឹងរួមចំណែកលើកស្ទួយគុណតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលមានចរិតក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ ក៏ដូចជារួមចំណែកលើកកម្ពស់ការទទួលខុសត្រូវរបស់អ្នកដឹកនាំនយោបាយ ដែលមានបំណងឈរឈ្មោះឱ្យគេបោះឆ្នោត ក្នុងការគោរពករណីកិច្ចរបស់ខ្លួនក្នុងនាមជាពលរដ្ឋល្អ ក្នុងសង្គមប្រជាធិបតេយ្យ»។




អ្នកសារព័ត៌មាន មកស្តាប់ការអនុម័តសេចក្តីព្រាងច្បាប់«វិសោធនកម្មច្បាប់បោះឆ្នោត» ក្នុងរដ្ឋសភា នៅរាជធានីភ្នំពេញ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣។(លាស់ លីបលីប/ វីអូអេ)

វិសោធនកម្មច្បាប់បោះឆ្នោតដែលត្រូវបានស្នើដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានកំណត់ផ្តន្ទាទោសលើជនទាំងឡាយណា ដែលបង្កការរារាំង ឬញុះញង់មិនឱ្យពលរដ្ឋទៅបោះឆ្នោត ឬណែនាំពលរដ្ឋឱ្យគូសសន្លឹកឆ្នោតចោល។ ជនឬគណបក្សនយោបាយអាចប្រឈមការផាកពិន័យជាប្រាក់ចាប់ពី ៥ លានទៅដល់ ៣០ លានរៀល ដែលមិនទាន់គិតពីទោសព្រហ្មទណ្ឌ និងឈានទៅដកហូតសិទ្ធិនយោបាយជាដើម។

វិសោធនច្បាប់បោះឆ្នោតដែលលោក ហ៊ុន សែន បានស្នើឱ្យអនុម័តមុនការបោះឆ្នោតនាថ្ងៃទី ២៣ ខែកក្កដា ធ្វើឡើងដើម្បីឆ្លើយតបទៅនឹងយុទ្ធនាការ WIFI របស់ក្រុមប្រឆាំង ដែលរដ្ឋាភិបាលកម្ពុជាអះអាងថា ក្រុមនេះមិនចង់ទៅបោះឆ្នោត ឬទៅបោះឆ្នោតដោយគូសសន្លឹកឆ្នោតចោល។

កាលពីថ្ងៃទី ១៩ ខែមិថុនា ក្នុងកិច្ចប្រជុំបូកសរុបសកម្មភាព និងលទ្ធផលការងារក្រុមការងាររដ្ឋាភិបាលនីតិកាលទី ៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថា មានតែប្រើ «វិធានការច្បាប់» ប៉ុណ្ណោះទើបអាចកម្ចាត់ក្រុមអ្នកនយោបាយប្រឆាំង ដែលគ្រោងធ្វើយុទ្ធនាការ WIFI «មិនចង់ទៅបោះឆ្នោត ឬទៅបោះឆ្នោតដោយគូសសន្លឹកឆ្នោតចោល»។

លោកថ្លែងថា៖ «ប៉ុន្តែដល់អ្នកឯងធ្វើហួស គឺយើងគ្មានជម្រើសណាក្រៅពីវិធានការច្បាប់ទេ។ ហើយបើច្បាប់ចេញហើយ អ្នកឯងប្រថុយជាមួយច្បាប់ វាមានតែគុកព្រៃស ត្រពាំងផ្លុង ព្រះវិហារ។ អាគុកហ្នឹងគេធ្វើ សម្រាប់ដាក់មនុស្សខូចតាស»។

លោក ហ៊ុន សែន បន្ថែមថា នេះជាការសម្លាប់សិទ្ធិនយោបាយរបស់បុគ្គលណាដែលមិនទៅបោះឆ្នោតនាខែកក្កដាខាងមុខនេះ។

អ្នកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថ្លែងថា ខ្លឹមសារនៃច្បាប់បោះឆ្នោត គួរតែមានលក្ខណៈអំណោយផលសម្រាប់ទាំងអ្នកឈរឈ្មោះបោះឆ្នោត និងអ្នកចូលរួមបោះឆ្នោត ដោយមិនគួរមានការកំហិតទេ ព្រោះវានឹងប៉ះពាល់ដល់ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

អ្នកស្រីប្រាប់វីអូអេនៅថ្ងៃសុក្រនេះថា៖ «ការលើកឡើងក្នុងការពន្យល់ [វិសោធនកម្មច្បាប់]ហ្នឹង គឺក្នុងគោលដៅ ដើម្បីលើកកម្ពស់គុណតម្លៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ ប៉ុន្តែបើយើងមើលខ្លឹមសារនៃការធ្វើវិសោធនកម្មនេះទៅវិញ វាអត់បានគាំទ្រ ទៅលើការលើកស្ទួយគុណតម្លៃនេះទេ ព្រោះវាបានដាក់កំហិតទៅលើបេក្ខជន ដែលនឹងឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ។ ហើយយើងដឹងហើយការបោះឆ្នោត ឬមិនទៅបោះឆ្នោត អាហ្នឹងជារឿងសិទ្ធិ ហើយខ្ញុំគិតថា តំណាងរាស្ត្រមួយចំនួនក៏បានទទួលស្គាល់នូវលក្ខខណ្ឌហ្នឹងដែរ។ ប៉ុន្តែទោះបីទទួលស្គាល់យ៉ាងណាក៏ដោយ យើងនៅតែនាំគ្នាអនុម័ត ទៅលើលក្ខខណ្ឌដែលបានផ្ទុយអំពីគោលការណ៍សិទ្ធិនេះទៅវិញ»។

អ្នកស្រីបន្ថែមថា៖ «បើសិនជាយើងលើកឡើងថា ការធ្វើវិសោធនកម្មនេះ គឺដើម្បីលើកស្ទួយនូវគុណតម្លៃលទ្ធិប្រជាធិបតេយ្យនោះ ខ្លឹមសារទាំងឡាយវាគួរតែមានលក្ខណៈអំណោយផលសម្រាប់ទាំងអ្នកដែល

ឈររឈ្មោះបោះឆ្នោត និងអ្នកចូលរួមបោះឆ្នោត។ ប៉ុន្តែបើសិនជាមានលក្ខណៈកំហិតណាមួយនោះ អ៊ីចឹងវានឹងមិនបម្រើនូវផលប្រយោជន៍នៃការលើកស្ទួយលទ្ធិប្រជាធិបតេយ្យនោះទេ»។

បើតាមអ្នកស្រី ចក់ សុភាព នេះមិនមែនជាលើកទី ១ ទេ ដែលរដ្ឋាភិបាលកម្ពុជាធ្វើវិសោធនកម្មច្បាប់ ព្រោះកាលពីឆ្នាំ ២០១៣ រដ្ឋាភិបាលកម្ពុជា ក៏បានធ្វើវិសោធនកម្មច្បាប់ផងដែរ ដែលពេលនោះឈានទៅរំលាយគណបក្សប្រឆាំងដ៏ធំ គឺគណបក្សសង្គ្រោះជាតិ។

អ្នកស្រីបន្ថែមថា ការធ្វើវិសោធនកម្មច្បាប់អ្វីមួយគួរតែអនុលោមទៅតាមគោលការណ៍សិទ្ធិមនុស្ស ដើម្បីធានាដល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាពិសេសត្រូវសិក្សា ត្រួតពិនិត្យ វិភាគ និងប្រមូលធាតុចូលឱ្យបានគ្រប់គ្រាន់ ទើបអាចឱ្យគ្រប់ភាគីទទួលយកបាន និងដើម្បីអាចឆ្លើយតបទៅតាមគោលការណ៍នីតិរដ្ឋ។

ក្រៅពីនេះ អ្នកស្រីកត់សម្គាល់ថា ខ្លឹមសារមួយចំនួនក្នុងវិសោធនកម្មច្បាប់បោះឆ្នោតនេះ មានភាពទូលាយច្រើន ដែលងាយប៉ះពាល់ ឬធ្វើឱ្យបាត់បង់សិទ្ធិឈរឈ្មោះរបស់បេក្ខជនមួយចំនួន។

វិសោធនកម្មច្បាប់នេះនឹងត្រូវបញ្ជូនទៅព្រឹទ្ធសភាដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ដើម្បីពិនិត្យបន្ត មុននឹងដាក់ថ្វាយព្រះ

មហាក្សត្រ ដើម្បីប្រកាសឱ្យប្រើប្រាស់ជាប្រញាប់ឱ្យបានមុនការបោះឆ្នោតថ្នាក់ជាតិ នាថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០២៣ ខាងមុខ៕